ការបោះឆ្នោតឆ្នាំ 2024

# របៀបបោះឆ្នោតគាំទ្រ ប្រធានាធិបតី

## បានចុះឈ្មោះបោះឆ្នោតដោយគ្មាននិន្នាការនយោបាយលើគណបក្សណាមួយ/គ្មានគណនបក្សឬ?

ក្នុងនាមជាអ្នកបោះឆ្នោតដែលបានបដិសេធក្នុងការផ្តល់និន្នាការនយោបាយលើគណបក្សនយោបាយណាមួយ ឬអ្នកបានចុះឈ្មោះជាមួយគណបក្សនយោបាយដែលមិនស្គាល់ ឬមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ អ្នកត្រូវបានចាត់ទុកថាជាអ្នកបោះឆ្នោតដែលជា “អ្នកគ្មាននិន្នាការនយោបាយលើគណបក្សណាមួយ” (No Party Preference, NPP) ហើយ**សន្លឹកឆ្នោតនៃការបោះឆ្នោតបឋមរបស់អ្នកនឹងមិនមានបេក្ខជនប្រធានាធិបតីនៅលើនោះទេ។**

ប្រសិនបើអ្នកចង់បោះឆ្នោតគាំទ្រប្រធានាធិបតីសហរដ្ឋអាមេរិក អ្នកត្រូវតែស្នើសុំសន្លឹកឆ្នោតដែលមានបេក្ខជនប្រធានាធិបតីពីគណបក្សមួយក្នុងចំណោមគណបក្សដូចខាងក្រោម៖

- គណបក្សអាមេរិកាំងឯករាជ្យ
- គណបក្សប្រជាធិបតេយ្យ
- គណបក្សអ្នកសេរីនិយម

ប្រសិនបើអ្នកចង់បោះឆ្នោតគាំទ្របេក្ខជនប្រធានាធិបតីរបស់គណបក្សបៃតង សន្តិភាព និងសេរីភាព ឬគណបក្សសាធារណរដ្ឋ អ្នកត្រូវតែចុះឈ្មោះម្តងទៀតជាមួយគណបក្សជាក់លាក់នោះ។

## បានចុះឈ្មោះបោះឆ្នោតជាមួយគណបក្សនយោបាយដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ឬ?

ប្រសិនបើអ្នកបានចុះឈ្មោះជាមួយគណបក្សនយោបាយដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចខាងក្រោម អ្នកអាចបោះឆ្នោតគាំទ្របានតែបេក្ខជនប្រធានាធិបតីរបស់គណបក្សនោះប៉ុណ្ណោះ៖

- គណបក្សអាមេរិកាំងឯករាជ្យ
- គណបក្សប្រជាធិបតេយ្យ
- គណបក្សបៃតង
- គណបក្សអ្នកសេរីនិយម
- គណបក្សសន្តិភាពនិងសេរីភាព
- គណបក្សសាធារណរដ្ឋ

ប្រសិនបើអ្នកចង់បោះឆ្នោតគាំទ្របេក្ខជនប្រធានាធិបតីរបស់គណបក្សផ្សេង អ្នកត្រូវតែចុះឈ្មោះ-ម្តងទៀតជាមួយគណបក្សជាក់លាក់នោះ។

## សាកសួរបុគ្គលិកបោះឆ្នោត ដើម្បីទទួលបានព័ត៌មានបន្ថែម។